ANNA & ASSOCIATES
Law Office

## ព័ត៌មានថ្មីៗ – ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ

# ប្រកាសលេខ ១១៧ ព.ណ.ចបព.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្ម៖ ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំសម្រាប់សហគ្រាសពាណិជ្ជកម្ម

*ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៦ – រាជធានីភ្នំពេញ – ព្រះរាជាណាចក្រកម្ពុជា*

កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥ ក្រសួងពាណិជ្ជកម្ម បានចេញប្រកាសលេខ ១១៧ ព.ណ.ចបព.ប្រក ស្តីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម (“**ប្រកាស**”)។ ប្រកាសនេះបានប្រមូលផ្តុំ និងបញ្ជាក់បន្ថែមដល់បទដ្ឋានគតិយុត្តផ្សេងទៀតសម្រាប់ការចុះបញ្ជីអាជីវកម្ម។ គោលបំណងសំខាន់របស់ប្រកាសនេះគឺ ដើម្បីបង្កើនប្រសិទ្ធភាព ភាពងាយស្រួលក្នុងការចូលដំណើរការ និងប្រសិទ្ធផលនៃនីតិវិធីចុះបញ្ជីអាជីវកម្មនៅកម្ពុជា។

ជាក់ស្តែង, ក្នុងជំពូកទី ៨ នៃប្រកាសនេះបានកំណត់អំពីកាតព្វកិច្ចទាក់ទងនឹងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ។ រាល់ក្រុមហ៊ុនទាំងអស់ សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស ដែលបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ត្រូវតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំអំពីស្ថានភាពប្រតិបត្តិការរបស់ខ្លួន។ ប្រកាសនេះត្រូវដាក់ស្នើតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម។

បន្ថែមពីនេះ, ក្រសួងពាណិជ្ជកម្មក៏បានចេញសេចក្តីជូនដំណឹងស្តីពី ការលើកលែងពិន័យចំពោះក្រុមហ៊ុនខកខានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមរយៈការពិន័យ ១ឆ្នាំចុងក្រោយ (“**សេចក្តីជូនដំណឹង**”) ដើម្បីលើកទឹកចិត្តក្រុមហ៊ុនឱ្យដាក់ពាក្យស្នើសុំតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំឡើងវិញ។ សេចក្តីជូនដំណឹងនេះបានកំណត់គោលនយោបាយលើកលែងពិន័យក្រោមលក្ខខណ្ឌដូចខាងក្រោម៖ ១. ក្រុមហ៊ុនត្រូវបង់ប្រតិវេទន៍រយៈពេល ១ឆ្នាំចុងក្រោយ នៅក្រសួងពាណិជ្ជកម្មក្នុងអំឡុងពេល ៦០ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទី **០៨ ខែមករា ឆ្នាំ ២០២៦** និង ២. ក្រុមហ៊ុនត្រូវចូលរួមក្នុងដំណើរការពិនិត្យសាវតារបស់ម្ចាស់ភាគហ៊ុន (Background Check) ដើម្បីរួមចំណែកក្នុងការពង្រឹងការងារប្រយុទ្ធប្រឆាំងការលាងសម្អាតប្រាក់។ ដូចនេះ អត្ថបទខាងក្រោមនេះ នឹងសម្រាយជូនអំពី៖ ១. ឯកសារដែលត្រូវការសម្រាប់ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំសម្រាប់សហគ្រាសពាណិជ្ជកម្ម, ២. រយៈពេលអនុគ្រោះ និងផលវិបាកសម្រាប់ក្រុមហ៊ុនដែលមិនបានដាក់ស្នើប្រកាសប្រចាំឆ្នាំ និង ៣. ពិន័យសម្រាប់ក្រុមហ៊ុនដែលមិនបានដាក់ស្នើប្រកាសប្រចាំឆ្នាំតាមពេលកំណត់។

---



***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

## ១. តើឯកសារតម្រូវមានអ្វីខ្លះ ?

ព័ត៌មាន និងសំណុំឯកសារសម្រាប់ការតម្កល់ប្រតិវេទន៍ដែលត្រូវបញ្ចូលនៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មតាមគេហទំព័រ www.businessregistration.moc.gov.kh និងមានទម្រង់ដូចខាងក្រោម៖

ក. ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ សម្រាប់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនសហកម្មសិទ្ធិ សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស៖

១. លេខអត្តសញ្ញាណកម្មសារពើពន្ធ
២. កាលបរិច្ឆេទចុះបញ្ជីសារពើពន្ធ
៣. ប័ណ្ណពន្ធប៉ាតង់នៃឆ្នាំដែលត្រូវប្រកាសប្រតិវេទន៍សម្រាប់រាល់សកម្មភាពអាជីវកម្មដែលកំពុងមានប្រតិបត្តិការ
៤. ចំនួនបុគ្គលិក និងឯកសារភ្ជាប់ ស្ដីពីតួនាទីនិយោជិកជាក់ស្ដែង
៥. អ៊ីមែល និងលេខទូរសព្ទក្រុមហ៊ុន ដែលកំពុងប្រើប្រាស់

ខ. ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ សម្រាប់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត៖

១. លេខអត្តសញ្ញាណកម្មសារពើពន្ធ
២. កាលបរិច្ឆេទចុះបញ្ជីសារពើពន្ធ
៣. ប័ណ្ណពន្ធប៉ាតង់នៃឆ្នាំដែលត្រូវប្រកាសប្រតិវេទន៍សម្រាប់រាល់សកម្មភាពអាជីវកម្មដែលកំពុងមានប្រតិបត្តិការ
៤. ចំនួនបុគ្គលិក និងឯកសារភ្ជាប់ស្ដីពីតួនាទីនិយោជិក
៥. អ៊ីមែល និងលេខទូរសព្ទក្រុមហ៊ុនដែលកំពុងប្រើប្រាស់
៦. របាយការណ៍ហិរញ្ញវត្ថុ និងបញ្ជីម្ចាស់ហ៊ុន

---

## ២. តើរយៈពេលនៃការអនុគ្រោះលើការពិន័យ និងផលវិបាកនៃការមិនតម្កល់ប្រតិវេទន៍មានអ្វីខ្លះ ?

រាល់បណ្ដាក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងនៃក្រុមហ៊ុនបរទេស ត្រូវបានកំណត់ឱ្យបំពេញកាតព្វកិច្ចក្នុងការតម្កល់ប្រតិវេទន៍ជារៀងរាល់ឆ្នាំ។ ក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងនៃក្រុមហ៊ុនបរទេសតម្រូវឱ្យតម្កល់ប្រតិវេទន៍ក្នុងអំឡុងពេលមុន **៣(បី) ខែ**នៃថ្ងៃខួបកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្មរបស់ខ្លួននីមួយៗ។

ក្នុងករណីក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងនៃក្រុមហ៊ុនបរទេសខកខានមិនបានបំពេញ កាតព្វកិច្ចតម្កល់ប្រតិវេទន៍ក្នុងរយៈពេលដែលបានកំណត់ខាងលើក្រសួងនឹងអនុគ្រោះដោយទុករយៈពេលចំនួន **១៥ (ដប់ប្រាំ) ថ្ងៃ**បន្ថែមទៀត សម្រាប់ការតម្កល់ប្រតិវេទន៍។

---



***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

### ៣. តើនឹងមានផលវិបាកអ្វីខ្លះនៃការមិនបានតម្កល់ប្រតិវេទន៍ទាន់ពេលវេលា?

ក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និង ការិយាល័យតំណាងក្រុមហ៊ុនបរទេស ទាំងឡាយណា ដែលខកខាន មិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំត្រឹមថ្ងៃផុតកំណត់នឹងត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន **២,០០០,០០០ (ពីរលាន) រៀល**។

ក្នុងករណី ក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និង ការិយាល័យតំណាង ក្រុមហ៊ុនបរទេស ដែលខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំចាប់ពី**១ (មួយ) ឆ្នាំឡើងទៅ**នឹងត្រូវបង់ប្រាក់ពិន័យព្រមទាំងបង់កម្រៃសេវាប្រតិវេទន៍ប្រចាំឆ្នាំទៅតាមចំនួន ឆ្នាំដែលខកខាន។

ក្នុងករណីក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស ខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំចាប់ពី **៣ (បី) ឆ្នាំ**ជាប់គ្នា នឹងត្រូវចាត់ទុកជា**ក្រុមហ៊ុនអកម្ម**។

ម្ចាស់ហ៊ុន និងអភិបាលនៃក្រុមហ៊ុនអកម្ម ត្រូវជាប់នៅក្នុង**បញ្ជីប្រុងប្រយ័ត្ន** ដែលមិនអនុញ្ញាតឱ្យទទួលបាននូវការបម្រើសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម រួមមាន ការស្នើសុំចុះបញ្ជីបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ការស្នើសុំចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរ និងកែប្រែផ្សេងៗរបស់ក្រុមហ៊ុន។

**ក្រុមហ៊ុនអកម្ម** អាចជាកម្មវត្ថុក្នុងការបន្តនីតិវិធីលើការរំលាយ និង**លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មតាមច្បាប់ជាធរមាន**បន្ទាប់ពីបានបំពេញកាតព្វកិច្ចបំណុលពន្ធតាមរយៈសវនកម្មជម្រះបញ្ជីពីអគ្គនាយកដ្ឋានពន្ធដារ ហើយទទួលបានលិខិតបញ្ជាក់ស្តីពីការបិទក្រុមហ៊ុនជាស្ថាពររួចរាល់។

---


**ទំនាក់ទំនងមកកាន់៖**

**ការិយាល័យមេធាវី អេណា និងសហការី**

**គេហទំព័រ**: www.anna-associates.com

**អ៊ីម៉ែល**: info@anna-associates.com

**លេខទូរស័ព្ទ**: (+៨៥៥) ៩៩ ៨៨៨ ៧៣៧

**អាសយដ្ឋាន៖**

**អាសយដ្ឋានការិយាល័យ**: អាគារលេខ២៣៤ ជាន់ទី៧ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា





***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*